ក្រសួងសុខាភិបាល Ministry of Health | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង Communicable Disease Control Department

Notice
Can't identify browser version. Agent: Mozilla/5.0 (Macintosh; Intel Mac OS X) AppleWebKit/534.34 (KHTML, like Gecko) Qt/4.8.7 Safari/534.34

## បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា




**COVID-19 Updated 23-03-2020**

រហូតម៉ោង ១១យប់ ថ្ងៃទី ២៤ មីនា ២០២០ យើងរកឃើញអ្នកជំងឺ COVID-19 ៤នាក់ (អង់គ្លេស២ អាមេរិក២) សរុបទាំងអស់ប្រទេសយើងមានចំនួន  ៩១ករណី និង យើងបានព្យាបាលជាសះស្បើយ ចំនួន៦នាក់ ស្លាប់គ្មាន សូមអានតារាងខាងក្រោម។ យើងពុំទាន់រកឃើញភស្តុតាង បញ្ជាក់ថាមានការឆ្លងក្នុងសហគមន៍ នៅឡើយទេ តែលទ្ធភាពនឹងអាចកើតមានឡើង ។
ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥
https://covid19-map.cdcmoh.gov.kh
អរគុណ inSTEDD





Read more: បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

## សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និងមន្ត្រីនាយកដ្ឋាន ប្រយុទ្ធនឹងជំងឺឆ្លង

***Date: 23/March/2020***

យើងខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដូចមានរាយនាមខាងក្រោម ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុកទូរស័ព្ទទាន់ហេតុការណ៍ ១១៥ (២៤ម៉ោង/៧ថ្ងៃ) និងមន្ត្រីនាយកដ្ឋានដើម្បីលើកទឹកចិត្ត និងរួមចំណែកក្នុងការប្រយុទ្ធ និងទប់ស្កាត់ជំងឺកូវីដ១៩ សូមប្រសិទ្ធពរបវរសួស្តីមហាប្រសើរ ជូនដល់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។
យើងខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលបានឧបត្ថម្ភ និងលើកទឹកចិត្តដល់យើងខ្ញុំផងដែរ។

ថ្ងៃ ចន្ទ ១៥រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០





## សារអប់រំទាក់ទងនឹងកូវី ១៩

***Date: 23/March/2020***

ព័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥




## នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល

***Date: 22/March/2020***

សូមបងប្អូនដែលទើបធ្វើដំណើរ ត្រលប់ពីបរទេសទាំងអស់ សូមមេត្តាដាក់ខ្លួនឯង ឲ្យនៅដាច់ដោយឡែក ចំនួន១៤ថ្ងៃ និងតាមដានសុខភាព បើមានចេញរោគសញ្ញា សូមពិគ្រោះជំងឺជាមួយទូរស័ព្ទលេខ ១១៥ ។ សូមអានសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ។



## មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់

***Updated: 19/March/2020***

 





មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅតាមរយៈក្អកឬកណ្តាស (មិនមែនហោះហើរក្នុងខ្យល់ទេ) ។ ត្រូវចងចាំថា ដំណក់ទឹកតូចៗអ្នកជំងឺដល់ទីណា មេរោគនឹងទៅដល់ទីនោះ ។អ្នកវិទ្យាសាស្ត្ររកឃើញថា ចំងាយខ្ទាតចេញពីមុខមនុស្សយើងចំងាយបាន ៣ហ្វីត បើគិតពីរង្វាស់ម៉ែត្រគឺ ៩០សង់ទីម៉ែត្រ ។ ដូច្នេះបើយើងនៅឆ្ងាយពីអ្នកជំងឺលើសពី១ម៉ែត្រ យើងនឹងគេចផុតពីដំណក់ទឹកតូចៗទាំងនោះ ។
ពេលអ្នកជំងឺក្អកឬកណ្តាសម្តងៗ បណ្តាលឱ្យខ្ទាតទៅលើផ្ទៃផ្សេងៗ ដូចជាលើតុ លើជញ្ជាំង លើបង្កាន់ដៃ ។ល។ និងដៃរបស់គាត់ក្រោយញីច្រមុះប្រលាក់សំបោរ ប៉ះដៃទ្វារប៉ះជញ្ជាំងប៉ះបង្កាន់ដៃ ដែលអ្នកជាប៉ះផ្ទៃទាំងនោះបណ្តាលឱ្យឆ្លងពេលយើងប៉ះមុខនិងច្រមុះ ។អ្នកវិទ្យាសាស្ត្ររកឃើញថា ក្នុងមួយថ្ងៃមនុស្សយើងប៉ះមុខជាមធ្យម ៦០ដង ។ ហេតុដូច្នេះ តំរូវឱ្យអ្នកជំងឺត្រូវពាក់ម៉ាស់ដើម្បីកុំឱ្យខ្ទាតចេញមកក្រៅ នឹងទាំងអ្នកឈឺនិងអ្នកជាត្រូវតែឧស្សាហ៍លាងដៃជាមួយសាប៊ូ អាល់កុល ជេល ជាដើម ។ ចំពោះអ្នកជាពុំចាំបាច់ពាក់ម៉ាស់ទេ គឺយើងពាក់ម៉ាស់នៅពេលចាំបាច់ដូចជាកន្លែងប្រមូលផ្តុំ សួរសុខទុក្ខអ្នកជំងឺ និងក្រុមគ្រូពេទ្យ ហើយគ្រវាត់ម៉ាស់ក្នុងធុងសំរាមភ្លាមក្រោយប្រើប្រាស់ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥


- លេខ ១១៥ មានអ្នកទូរស័ព្ទចូលរហូតដល់ ជាង៩៣ម៉ឺននាក់ គិតចាប់ពីពេលរកឃើញកូវិត១៩ ករណីទី១មក
- A passenger on flight PG933 from Bangkok to Phnom Penh (9 MARCH 2020) has tested positive for COVID19
- របៀបដោះស្រាយ នៅពេលយើងមានបញ្ហាផុញថប់ តានតឹង ក្នុងកំឡុងពេលមានការរកឃើញ ករណីជំងឺកូវិត១៩ ជាបន្តបន្ទាប់ ក្នុងប្រទេសយើង
- ក្រសួងសុខាភិបាលកម្ពុជា ដាក់បំរាមផ្អាកមិនអោយជនបរទេស ដែលមកពីប្រទេស អ៊ីតាលី អាល្លឺម៉ង់ អេស្ប៉ាញ បារាំង និង អាមេរិក ចូលមកក្នុងប្រទេសកម្ពុជា

Page 1 of 63

Home

Press Release
- Avian Influenza
- SARS
- Severe Watery Diarrhea
- Swine Influenza
- Other Disease
- MERS

Bulletins
- Year 9 (2012)
- Year 8 (2011)
- Year 7 (2010)
- Year 6 (2009)
- Monthly respiratory buttletin
  - Year 2014
  - Year 2015
  - Year 2016
  - Year 2017

IEC material and documents
- Posters

## Latest Articles

- បច្ចុប្បន្នភាពនៃជំងឺកូវីដថ្មី COVID-19 នៅប្រទេសកម្ពុជា
- COVID-19 Documents Management
- សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅជូនចំពោះ សប្បុរសជន ដែលបានឧបត្ថម្ភថវិកា ដល់មន្ត្រីទទួលបន្ទុក ទូរស័ព្ទទាន់ហេតុការណ៍ ១១៥ និងមន្ត្រីនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
- សារអប់រំទាក់ទងនឹងកូវី ១៩
- នីតិវិធីដាក់ខ្លួន អោយនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការ និងទប់ស្កាត់ជំងឺកូវីត១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល

## Login Form

User Name

Password

Remember Me

Log in

Forgot your username?
Forgot your password?

## Visitors Counter

| | |
|---|---|
| Today | 2445 |
| Yesterday | 3599 |
| This week | 9907 |
| This month | 46587 |
| Total | 978980 |

Powered by CoalaWeb

© 2020 CDC Department Website